ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៥៦៣ សហវ.ប្រក

# ប្រកាស
# ស្តីពី
# ពន្ធលើប្រាក់បៀវត្ស

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីតារាងភាគនៃប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំនិងតារាងភាគនៃប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ
- បានឃើញប្រកាសលេខ ១១៧៣ សហវ.ពដ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៣ ស្តីពីពន្ធលើប្រាក់បៀវត្ស
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.- គោលបំណង**

ប្រកាសនេះ មានគោលបំណងកែសម្រួល និងធ្វើបច្ចុប្បន្នភាពប្រកាសនិងបទប្បញ្ញត្តិនានាទាក់ទិននឹងពន្ធលើប្រាក់បៀវត្ស ដើម្បីឆ្លើយតបនឹងការរីកចម្រើនសេដ្ឋកិច្ចកម្ពុជា និងធានាបាននូវប្រសិទ្ធភាពនៃការប្រមូលចំណូលពន្ធ។

**ប្រការ ២.- វិសាលភាព**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះរូបវន្តបុគ្គលនិវាសនជននៅក្នុងព្រះរាជាណាចក្រកម្ពុជាចំពោះប្រាក់បៀវត្សប្រភពកម្ពុជានិងប្រាក់បៀវត្សប្រភពបរទេស និងរូបវន្តបុគ្គលអនិវាសនជនចំពោះប្រាក់បៀវត្សប្រភពកម្ពុជា។

**ប្រការ ៣.- និយមន័យ**

សម្រាប់គោលដៅនៃប្រកាសនេះ÷

១- ពាក្យ "ប្រាក់បៀវត្ស" សំដៅដល់ បៀវត្ស លាភការ ប្រាក់បំណាច់ បុព្វលាភ ប្រាក់ម៉ោងបន្ថែម ប្រាក់ប៉ះប៉ូវនានា និងអត្ថប្រយោជន៍បន្ថែម ដែលបានទូទាត់ឱ្យដល់និយោជិត ឬដែលបានទូទាត់ដើម្បីជាប្រយោជន៍ផ្ទាល់ ឬប្រយោលដល់និយោជិត ចំពោះការបំពេញសកម្មភាពបម្រើការងាររបស់និយោជិត។

ក- ពាក្យ "បៀវត្ស" សំដៅដល់ ប្រាក់ឈ្នួលដែលទូទាត់ជូននិយោជិតចំពោះការបំពេញការងារ ទោះជាមូលដ្ឋានគិតជាប្រាក់ម៉ោងឬប្រាក់ថ្ងៃឬប្រាក់សប្តាហ៍ក្តី ឬជាអប្បបរមាក្តី ទោះជាបើកឱ្យដោយចំពោះឬមិនចំពោះក្តី ឬក៏បើកជាសាច់ប្រាក់ឬជាវត្ថុក្តី។ ពាក្យ "បៀវត្ស" ក៏រួមបញ្ចូលផងដែរនូវប្រាក់ហានិភ័យ (ការងារ តំបន់ ឬសុខភាព) ប្រាក់វិភាជន៍គ្រួសារ (ប្រពន្ធ ឬ/និងកូន) ប្រាក់រំលឹក។

ខ- ពាក្យ "លាភការ" សំដៅដល់ រង្វាន់នៃការអនុវត្តការងារ ដែលបន្ថែមលើប្រាក់ឈ្នួល ក្នុងន័យជាសគុណនៃការបំពេញកិច្ចការអ្វីមួយដល់និយោជក។

ឧទាហរណ៍ ÷ កញ្ញា ខ ជាគណនេយ្យករ នៅក្រុមហ៊ុន ក ដែលមានសកម្មភាពអាជីវកម្មជាគោលដើម គឺផ្គត់ផ្គង់ផលិតផលកសិកម្ម។ កញ្ញា ខ ត្រូវបានក្រុមហ៊ុនអញ្ជើញឱ្យជួយថតផ្សាយពាណិជ្ជកម្មដែលក្រុមហ៊ុននឹងផ្តល់កម្រៃពីការថតផ្សព្វផ្សាយពាណិជ្ជកម្ម។ ដូចនេះ ប្រាក់កម្រៃពីការថតផ្សាយពាណិជ្ជកម្មរបស់កញ្ញា ខ ត្រូវបានចាត់ទុកជា លាភការ។

គ- ពាក្យ "ប្រាក់បំណាច់" សំដៅដល់ ប្រាក់បំណាច់មុខងារ ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាចំពោះកិច្ចសន្យាការងារដែលមានកំណត់ចិរវេលា ឬប្រាក់បំណាច់អតីតភាពការងារចំពោះកិច្ចសន្យាការងារមានចិរវេលាមិនកំណត់ ឬប្រាក់បំណាច់បញ្ឈប់លែងឱ្យធ្វើការ និងប្រាក់បំណាច់ផ្សេងៗទៀត។

ឃ- ពាក្យ "បុព្វលាភ" សំដៅដល់ ប្រាក់រង្វាន់លើកទឹកចិត្ត ប្រាក់លើសផែនការ ប្រាក់បៀវត្សបន្ថែមលើប្រាក់បៀវត្សប្រចាំខែ និងប្រាក់លើកទឹកចិត្តប្រហាក់ប្រហែល ចំពោះការបំពេញការងាររបស់និយោជិត ដែលជាប្រយោជន៍អាជីវកម្មរបស់និយោជក។

ឧទាហរណ៍ ÷ ក្រុមហ៊ុន ក ជាក្រុមហ៊ុនអចលនទ្រព្យដែលទទួលបានប្រាក់ចំណូលលើសផែនការប្រចាំឆ្នាំ ហើយក្រុមហ៊ុនបានបើកប្រាក់រង្វាន់លើកទឹកចិត្តដល់និយោជិតម្នាក់ៗចំនួន ៣ខែ នៃប្រាក់បៀវត្សប្រចាំខែ។ ដូចនេះ ប្រាក់រង្វាន់លើកទឹកចិត្តដែលនិយោជិតទទួលបាន ត្រូវចាត់ទុកជា បុព្វលាភ។

ង- ពាក្យ "ប្រាក់ម៉ោងបន្ថែម" សំដៅដល់ ប្រាក់ដែលកម្មករនិយោជិតបានទទួលក្នុងក្របខ័ណ្ឌនៃការធ្វើការងារបន្ថែមម៉ោង ក្រៅម៉ោងពេលការងារជាធម្មតារបស់ខ្លួន។

ច- ពាក្យ "ប្រាក់ប៉ះប៉ូវ" សំដៅដល់ ប្រាក់ឧបត្ថម្ភដទៃទៀតដែលផ្តល់ឱ្យនិយោជិត ដោយសារការផ្លាស់ទីកន្លែងធ្វើការឆ្ងាយពីលំនៅឋាន ឬការងារដែលមានហានិភ័យជាដើម។

២- ពាក្យ "និយោជក" រួមមាន ស្ថាប័នរដ្ឋ នីតិបុគ្គលនិវាសនជន ក្រុមហ៊ុនសហកម្មសិទ្ធិនិវាសនជន គ្រឹះស្ថានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា អង្គការមិនស្វែងរកចំណេញ ឬរូបវន្តបុគ្គលនិវាសនជនដែលប្រកបអាជីវកម្ម។

៣- ពាក្យ "និយោជិត" សំដៅដល់ រូបវន្តបុគ្គលដែលបានទទួលប្រាក់បៀវត្សពីសកម្មភាពបម្រើការងាររបស់ខ្លួន រួមបញ្ចូលទាំងអ្នកទទួលខុសត្រូវ ឬអភិបាលរបស់សហគ្រាស មន្ត្រីរាជការ មន្ត្រីជ្រើសតាំងដោយការបោះឆ្នោតលើកលែងតែសមាជិករដ្ឋសភានិងព្រឹទ្ធសភា។

៤- ពាក្យ "និវាសនជន" ក្នុងករណីដែលប្រើចំពោះនិយោជិត អ្នកជាប់ពន្ធ ឬរូបវន្តបុគ្គល មានន័យថា ដែលមាននិវាសនដ្ឋាន ឬមានកន្លែងស្នាក់នៅជាគោលដើមនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬដែលមានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជាលើសពី ១៨២ថ្ងៃ នៅក្នុងរយៈពេល ១២ខែណាមួយដែលបានបញ្ចប់ក្នុងឆ្នាំជាប់ពន្ធចរន្ត។

៥- ពាក្យ "អនិវាសនជន" សំដៅដល់ រូបវន្តបុគ្គលណាម្នាក់ ដែលមិនមែនជានិវាសនជនតាមកថាខណ្ឌ ៤ នៃប្រការនេះ និងទទួលប្រាក់បៀវត្សប្រភពកម្ពុជា។

៦- ពាក្យ "ប្រាក់បៀវត្សប្រភពកម្ពុជា" សំដៅដល់ ប្រាក់បៀវត្សដែលបានទទួលក្នុងក្របខ័ណ្ឌនៃការបំពេញសកម្មភាពបម្រើការងារនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ដោយឡែក ចំពោះប្រាក់បៀវត្សដែលអនិវាសនជនបានទទួលក្នុងការផ្តល់ជំនួយបច្ចេកទេស ត្រូវចាត់ទុកថាមានប្រភពនៅក្នុងប្រទេសដែលអ្នកទូទាត់ប្រាក់បៀវត្សនោះស្នាក់នៅ។

៧- ពាក្យ "ប្រាក់បៀវត្សប្រភពបរទេស" សំដៅដល់ ប្រាក់បៀវត្សដែលបានទទួលក្នុងក្របខ័ណ្ឌនៃការបំពេញសកម្មភាពបម្រើការងារនៅក្រៅព្រះរាជាណាចក្រកម្ពុជា។

៨- ពាក្យ "អង្គការអន្តរជាតិ" សំដៅដល់ អង្គការអន្តររដ្ឋាភិបាលដែលបង្កើតឡើងក្រោមសន្ធិសញ្ញាអន្តរជាតិដើម្បីគិតគូរពីផលប្រយោជន៍សមាជិក ឬធ្វើសកម្មភាពបម្រើផលប្រយោជន៍សាធារណៈដោយធ្វើសកម្មភាពមិនស្វែងរកចំណេញ។

## ប្រការ ៤.- ស្ថានភាពបម្រើការងារ

បើប្រៀបធៀបទៅនឹងសកម្មភាពវិជ្ជាជីវៈ ឬសកម្មភាពនានាឯទៀត សកម្មភាពបម្រើការងារមានលក្ខណៈសម្គាល់តាមស្ថានភាពដែលនិយោជិតបំពេញសកម្មភាពបម្រើការងាររបស់ខ្លួននៅក្រោមឱវាទរបស់និយោជក។ រូបវន្តបុគ្គលណាម្នាក់ត្រូវបានចាត់ទុកថាជានិយោជិត ហើយត្រូវជាប់ពន្ធលើប្រាក់បៀវត្ស បើសិនរូបវន្តបុគ្គលនោះមានស្ថានភាពបម្រើការងារស្របតាមលក្ខខណ្ឌចំនួន ២ ក្នុងចំណោមលក្ខខណ្ឌទាំងឡាយខាងក្រោមនេះ÷

ក- គ្មានហានិភ័យនៃការមិនបានទទួលប្រាក់ទូទាត់ចំពោះសកម្មភាពបម្រើការងាររបស់ខ្លួនឡើយ កាលបើរូបវន្តបុគ្គលនោះបានមកធ្វើការតាមទីកន្លែងដែលបានកំណត់ ហើយបានបំពេញការងារដូចមានចែងក្នុងកិច្ចព្រមព្រៀងបម្រើការងារជាទូទៅមួយ ទោះធ្វើដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរក្តី

ខ- រូបវន្តបុគ្គលមិនអាចកំណត់ពេលវេលា និងទីកន្លែងសម្រាប់បំពេញសកម្មភាពបម្រើការងារដោយខ្លួនឯងទេ

គ- រូបវន្តបុគ្គលពុំចាំបាច់ចំណាយដើមទុនច្រើន ដើម្បីទិញឧបករណ៍ដែលត្រូវប្រើប្រាស់សម្រាប់បំពេញសកម្មភាពបម្រើការងារ

ឃ- រូបវន្តបុគ្គលមិនបំពេញសកម្មភាពបម្រើការងារឱ្យបុគ្គលច្រើននាក់ទេក្នុងពេលតែមួយ។

## ប្រការ ៥.- វិធាននៃនិវាសនដ្ឋាន និងប្រភព

១- សម្រាប់លក្ខណវិនិច្ឆ័យនៃនិវាសនដ្ឋាននៅកម្ពុជា រូបវន្តបុគ្គលណាម្នាក់ ដែលមានលក្ខណវិនិច្ឆ័យចាប់ពីមួយឡើងទៅក្នុងចំណោមលក្ខណវិនិច្ឆ័យទាំង ៣ ដូចខាងក្រោម ត្រូវបានចាត់ទុកជានិវាសនជននៅព្រះរាជាណាចក្រកម្ពុជា÷

ក- រូបវន្តបុគ្គលមាននិវាសនដ្ឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលជាកម្មសិទ្ធិឬជួល ឬភតិសន្យា ផ្ទះ អគារ បន្ទប់ជួល អន្តេវាសិកដ្ឋាន។ល។ ដែលអាចប្រើប្រាស់បាន ហើយដែលរូបវន្តបុគ្គលនោះតែងតែស្នាក់នៅឬកាន់កាប់

ខ- រូបវន្តបុគ្គលមានកន្លែងស្នាក់នៅជាគោលដើមនៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរូបភាពជាក់ស្តែងនៃការស្នាក់នៅ ដោយផ្អែកទៅលើកត្តានានា ដូចជា មជ្ឈមណ្ឌលសេដ្ឋកិច្ចរបស់រូបវន្តបុគ្គល រយៈពេលស្នាក់នៅ ចរិតនៃការស្នាក់នៅ ទីកន្លែងដែលគ្រួសាររបស់រូបវន្តបុគ្គលនោះស្នាក់នៅ គណនីធនាគាររបស់រូបវន្តបុគ្គល ទីកន្លែងដែលរូបវន្តបុគ្គលធ្វើសកម្មភាពសង្គមជាសំខាន់

គ- រូបវន្តបុគ្គលមានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជាលើសពី ១៨២ថ្ងៃក្នុងមួយលើក ឬច្រើនលើកក្នុងរយៈពេល ១២ខែណាមួយដែលបានបញ្ចប់ក្នុងឆ្នាំជាប់ពន្ធចរន្ត។ ក្នុងការកំណត់ចំនួនថ្ងៃស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា វត្តមានក្នុងចំណែកណាមួយនៃថ្ងៃត្រូវរាប់ថាជា ១ថ្ងៃពេញ។

ក្នុងករណីដែលមានភាពមិនច្បាស់លាស់ក្នុងការវិនិច្ឆ័យតាមលក្ខខណ្ឌដែលមានចែងក្នុងវាក្យខណ្ឌ ក និងវាក្យខណ្ឌ ខ នៃកថាខណ្ឌនេះ វត្តមានរបស់រូបវន្តបុគ្គលដែលមានចែងក្នុងវាក្យខណ្ឌ គ គឺជាលក្ខខណ្ឌចុងក្រោយសម្រាប់កំណត់ភាពជានិវាសនជនរបស់រូបវន្តបុគ្គល។

២- ដូចមានចែងក្នុងមាត្រា ៤១ នៃច្បាប់ស្តីពីសារពើពន្ធ ចំពោះរូបវន្តបុគ្គលនិវាសនជននៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រាក់បៀវត្សដែលបានទទួលនៅក្នុងនិងនៅក្រៅព្រះរាជាណាចក្រកម្ពុជា ត្រូវជាប់ពន្ធលើប្រាក់បៀវត្ស។

៣- ដូចមានចែងក្នុងមាត្រា ៤៩ ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ ចំពោះរូបវន្តបុគ្គលអនិវាសនជននៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រាក់បៀវត្សដែលបុគ្គលនេះបានទទួលអំពីសកម្មភាពបម្រើការងារនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវជាប់

ពន្ធលើប្រាក់បៀវត្ស លើកលែងតែប្រាក់បៀវត្សណាដែលជាការទូទាត់សម្រាប់សេវាបច្ចេកទេស ឬសេវាផ្សេងទៀត ហើយអ្នកបើកប្រាក់បៀវត្សឱ្យគ្មានវត្តមានក្រោមរូបភាពជាគ្រឹះស្ថានអចិន្ត្រៃយ៍ ឬមូលដ្ឋានប្រតិបត្តិការជាក់លាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៤- និយោជិតអាចរួចផុតពីកាតព្វកិច្ចបង់ពន្ធលើប្រាក់បៀវត្ស ដូចមានចែងក្នុងកថាខណ្ឌ ៣ នៃប្រការនេះ កាលបើបានបំពេញលក្ខខណ្ឌទាំង ៣ ដូចតទៅ÷

ក- និយោជិតមានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជាមិនលើសពី ១៨២ថ្ងៃក្នុងមួយលើក ឬច្រើនលើកក្នុងរយៈពេល ១២ខែណាមួយដែលបានបញ្ចប់ក្នុងឆ្នាំជាប់ពន្ធចរន្ត

ខ- និយោជិតទទួលប្រាក់បៀវត្សដែលត្រូវបានទូទាត់ដោយ ឬក្នុងនាមនិយោជកដែលមិនមែនជានិវាសនជននៅក្នុងព្រះរាជាណាចក្រកម្ពុជា

គ- និយោជិតទទួលប្រាក់បៀវត្សដែលមិនមែនជាបន្ទុករបស់គ្រឹះស្ថានអចិន្ត្រៃយ៍ ឬមូលដ្ឋានប្រតិបត្តិការជាក់លាក់ដែលនិយោជកបានបើកដំណើរការនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៥- ដើម្បីកំណត់ថាជានិយោជិតដែលត្រូវជាប់ពន្ធលើប្រាក់បៀវត្ស រដ្ឋបាលសារពើពន្ធត្រូវលើកយកមកពិចារណានូវដើមហេតុនានា ដូចជា÷

ក- បុគ្គលអ្នកទទួលខុសត្រូវ ឬទទួលរ៉ាប់រងការខូចខាតចំពោះការងារដែលបានអនុវត្ត

ខ- បុគ្គលអ្នកមានសិទ្ធិបញ្ជានិយោជិត

គ- បុគ្គលអ្នកគ្រប់គ្រងទីកន្លែងបំពេញការងារ បុគ្គលអ្នកកំណត់មូលដ្ឋានផ្តល់លាភការ និងកំណត់ទំនាក់ទំនងផ្សេងទៀតជាមួយនិយោជក

ឃ- បុគ្គលអ្នកផ្គត់ផ្គង់សម្ភារៈ និងឧបករណ៍ដែលនិយោជិតត្រូវប្រើប្រាស់

ង- បុគ្គលអ្នកកំណត់ចំនួន និងកម្រិតសមត្ថភាពរបស់និយោជិតដែលត្រូវជួលឱ្យបម្រើការងារ។

៦- សម្រាប់គោលដៅនៃពន្ធលើប្រាក់បៀវត្ស លក្ខណសម្បត្តិជានិវាសនជនត្រូវកំណត់តាមកថាខណ្ឌ ១ នៃមាត្រា ៤២ ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ ដោយមិនគិតពីស្ថានភាពខាងអន្តោប្រវេសន៍ទេ។

## ជំពូកទី២
## ប្រាក់បៀវត្ស

### ប្រការ ៦.- កម្មវត្ថុនៃពន្ធ

ពន្ធលើប្រាក់បៀវត្ស គឺជាពន្ធប្រចាំខែកំណត់លើប្រាក់បៀវត្ស ដែលបានទទួលក្នុងក្របខ័ណ្ឌនៃការបំពេញសកម្មភាពបម្រើការងារ។

### ប្រការ ៧.- ប្រាក់បៀវត្សជាប់ពន្ធ

ប្រាក់បៀវត្សជាប់ពន្ធ គឺជាប្រាក់ចំណូលបៀវត្សទាំងអស់ដែលបានទទួលពីសកម្មភាពបម្រើការងារនានា វៀរលែងតែអត្ថប្រយោជន៍បន្ថែម ដូចមានចែងក្នុងជំពូកទី៣ នៃប្រកាសនេះ។ ប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ ត្រូវបានកំណត់ដូចខាងក្រោម÷

១- ចំពោះនិយោជិតនិវាសនជនរួមមាន÷

ក- ប្រាក់បៀវត្សប្រភពកម្ពុជា

ខ- ប្រាក់បៀវត្សប្រភពបរទេស

គ- ប្រាក់បុរេប្រទាន ប្រាក់ឱ្យខ្ចីឬប្រាក់រំដោះ ដែលនិយោជកបានបើកឱ្យនិយោជិត។ ប្រាក់បុរេប្រទាន ប្រាក់ឱ្យខ្ចីឬប្រាក់រំដោះ ត្រូវបូកបន្ថែមលើបៀវត្សជាប់ពន្ធនៃខែដែលប្រាក់ទាំងនោះបានបើក ហើយត្រូវកាត់បន្ថយពីប្រាក់បៀវត្សក្នុងខែដែលនិយោជិតបានបង់សងវិញ។

២- ចំពោះនិយោជិតអនិវាសនជន ប្រាក់បៀវត្សជាប់ពន្ធរួមមានប្រាក់បៀវត្សប្រភពកម្ពុជា ដែលត្រូវជាប់ពន្ធតាមបទប្បញ្ញត្តិទាំងឡាយនៃជំពូកនេះ។

## ប្រការ ៨.- ប្រាក់ចំណូលលើកលែងពន្ធរបស់និយោជិត

ប្រាក់បៀវត្សដែលត្រូវបានលើកលែងពន្ធ មានដូចខាងក្រោម÷

១- ប្រាក់សំណងដោយពិតប្រាកដនូវចំណាយខាងវិជ្ជាជីវៈ ដែលបានចាយដោយនិយោជិតតាមសេចក្ដីបង្គាប់ និងសម្រាប់ជាប្រយោជន៍នៃនិយោជក ហើយដែលបានបំពេញលក្ខខណ្ឌ ៣ ដូចតទៅ÷

ក- បានចាយក្នុងផលប្រយោជន៍ផ្ទាល់និងដាច់ខាតរបស់សហគ្រាស

ខ- មិនបង្ហាញលក្ខណៈហួសប្រមាណឬស្ដុកស្ដម្ភហួសហេតុ

គ- បានបង្ហាញជាភ័ស្ដុតាងដោយវិក្កយបត្រវាយលម្អិតនិងបានទូទាត់ស្រេចបាច់ហើយ ដែលបានធ្វើក្នុងនាមអ្នកបានទទួលប្រាក់សំណងនូវចំណាយពិតប្រាកដ។

២- ប្រាក់បំណាច់នានានៃការបញ្ឈប់លែងឱ្យធ្វើការក្នុងកម្រិតដែលបានបញ្ញត្តក្នុងច្បាប់ការងារ។

៣- លាភការបន្ថែមមានលក្ខណៈខាងសង្គមកិច្ច ក្នុងករណីដែលបានបញ្ញត្តក្នុងច្បាប់ការងារ។

៤- ការផ្គត់ផ្គង់ឱ្យដោយឥតយកថ្លៃ ឬយកថ្លៃទាបជាងថ្លៃដើម នូវឯកសណ្ឋានឬបរិក្ខារសម្រាប់វិជ្ជាជីវៈពិសេស ត្រូវបានលើកលែងពន្ធលើប្រាក់បៀវត្ស ប្រសិនបើនិយោជិតត្រូវបង្វិលសម្ភារៈទាំងនោះសងទៅនិយោជកវិញនៅពេលឈប់បម្រើការងារ។ ដោយឡែកចំពោះឯកសណ្ឋាន គឺត្រូវមានលក្ខណៈចាំបាច់សម្រាប់បំពេញការងារ និងត្រូវបានផ្ដល់ឱ្យតាមបែបបទដូចគ្នាដល់និយោជិតទាំងអស់ដែលមានតួនាទីដូចគ្នា។

៥- ប្រាក់បំណាច់ម៉ោការសម្រាប់ចំណាយបេសកកម្មនិងការធ្វើដំណើរ ដែលត្រូវផ្ដល់ឱ្យសម្រាប់ជំនួសរបបទូទាត់សងវិញនូវចំណាយពិតប្រាកដដូចមានចែងក្នុងកថាខណ្ឌ ៥ នៃមាត្រា ៤៤ នៃច្បាប់ស្ដីពីសារពើពន្ធ មិនអាចលើសពីប្រាក់ឧបត្ថម្ភរបស់រដ្ឋសម្រាប់ការងារដូចគ្នាទេ។

## ប្រការ ៩.- បុគ្គលិករបស់បេសកកម្មទូត និងរដ្ឋាភិបាលបរទេស

ប្រាក់បៀវត្ស និងអត្ថប្រយោជន៍ផ្សេងទៀតដែលមន្ត្រីនិងនិយោជិតនៃបេសកកម្មទូត ឬកុងស៊ុលរបស់រដ្ឋាភិបាលបរទេសណាមួយដែលកាន់លិខិតឆ្លងដែនការទូត ឬផ្លូវការរបស់ប្រទេសនោះបានទទួលក្នុងក្របខ័ណ្ឌនៃការបំពេញមុខងារជាផ្លូវការនៅក្នុងព្រះរាជាណាចក្រកម្ពុជា មិនត្រូវជាប់ពន្ធលើប្រាក់បៀវត្សទេ។

## ប្រការ ១០.- និយោជិតនៃអង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេស

ប្រាក់បៀវត្ស និងអត្ថប្រយោជន៍ផ្សេងទៀត ដែលបានផ្ដល់ឱ្យអ្នកតំណាង មន្ត្រី និងនិយោជិតដែលត្រូវបានជួលឱ្យបម្រើការងារដោយទីស្នាក់ការជាគោលដើម និងរបស់អង្គការអន្តរជាតិនិងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលបរទេសនានាសម្រាប់សកម្មភាពបម្រើការងារជាផ្លូវការឱ្យអង្គការទាំងនេះ មិនត្រូវជាប់ពន្ធលើប្រាក់បៀវត្សទេ។

**ប្រការ ១១.- និយោជិតនៃគម្រោងជំនួយបច្ចេកទេស**

១- ក្រៅពីរូបវន្តបុគ្គលជានិវាសនជននៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលបម្រើការងារក្នុងមុខងាររដ្ឋបាល ឬជំនួយការធម្មតានៅក្នុងគម្រោងការជំនួយបច្ចេកទេសដែលត្រូវជាប់ពន្ធលើប្រាក់បៀវត្ស បណ្ដានិយោជិតដែលមានចុះបញ្ជាក់ក្នុងឯកសារគម្រោងការជំនួយបច្ចេកទេសរបស់អង្គការអន្តរជាតិ ឬទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលបរទេសណាមួយ ថាជាបុគ្គលិកជំនួយបច្ចេកទេស ត្រូវបានរួចពន្ធលើប្រាក់បៀវត្ស ក្រោយពេលដែលឯកសារគម្រោងការបានទទួលការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

២- បើសិនជាអង្គការអន្តរជាតិ ឬទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសចុះកិច្ចព្រមព្រៀងប្រគល់ការអនុវត្តគម្រោងការទៅឱ្យអ្នកម៉ៅការណាមួយ និយោជិតរបស់អ្នកម៉ៅការដែលបម្រើការងារជាបុគ្គលិកជំនួយបច្ចេកទេសដូចមានបញ្ជាក់នៅក្នុងឯកសារគម្រោងការដែលបានលើកឡើងនៅក្នុងកថាខណ្ឌ ១ នៃប្រការនេះ ត្រូវបានរួចពន្ធលើប្រាក់បៀវត្ស។ អ្នកម៉ៅការត្រូវកត់ត្រាឱ្យបានច្បាស់លាស់អំពីការងាររបស់បុគ្គលិកជំនួយបច្ចេកទេស និងបែងចែកឱ្យដាច់ពីគ្នាអំពីការងារក្រៅគម្រោងការ ឬអំពីបុគ្គលិកផ្សេងទៀតរបស់ខ្លួន។

**ប្រការ ១២.- មូលដ្ឋានគិតពន្ធលើប្រាក់បៀវត្ស**

១- មូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សប្រចាំខែ គឺជាទឹកប្រាក់ទូទាត់ទាំងអស់ ទោះជាសាច់ប្រាក់ក្ដី ឬជាវត្ថុក្ដី ដកចេញនូវទាយជ្ជទានសម្រាប់កូនក្នុងបន្ទុកនិងសហព័ទ្ធជាមេផ្ទះ វៀរលែងតែទឹកប្រាក់ទូទាត់ទាំងឡាយណាដែលត្រូវបានកំណត់ថាជាអត្ថប្រយោជន៍បន្ថែម ដូចមានចែងក្នុងជំពូកទី៣ នៃប្រកាសនេះ។

២- ផ្អែកលើការបង្ហាញភ័ស្តុតាងនៃស្ថានភាពគ្រួសារ និយោជិតនិវាសនជនណាមួយដែលមាន៖

ក- កូនស្ថិតក្នុងបន្ទុកនាពេលដែលត្រូវបង់ពន្ធ ត្រូវបានទទួលនូវការបន្ថយមូលដ្ឋានគិតពន្ធចំនួន ១៥០ ០០០ រៀល (មួយរយហាសិបពាន់រៀល) ក្នុងកូនម្នាក់ៗក្នុងមួយខែ

ខ- សហព័ទ្ធដែលធ្វើតែជាមេផ្ទះ ត្រូវបានទទួលនូវការបន្ថយមូលដ្ឋានគិតពន្ធចំនួន ១៥០ ០០០ រៀល (មួយរយហាសិបពាន់រៀល) សម្រាប់តែម្នាក់ក្នុងមួយខែ

គ- ចំពោះគ្រួសារមួយដែលមានឪពុកនិងម្ដាយមានប្រាក់បៀវត្សជាប់ពន្ធទាំងពីរនាក់ ការកាត់បន្ថយមូលដ្ឋានគិតពន្ធសម្រាប់កូនស្ថិតក្នុងបន្ទុក អាចអនុវត្តបានតែចំពោះប្រាក់បៀវត្សជាប់ពន្ធរបស់ឪពុក ឬម្ដាយតែម្នាក់ប៉ុណ្ណោះ។

៣- ដូចមានចែងក្នុងកថាខណ្ឌ ១ នៃមាត្រា ៤៦ នៃច្បាប់ស្ដីពីសារពើពន្ធ ប្រាក់ទាំងអស់ដែលនិយោជកឱ្យនិយោជិតក្នុងរូបភាពជាប្រាក់បុរេប្រទាន ប្រាក់ឱ្យខ្ចីឬប្រាក់រំដោះ ត្រូវបូកបញ្ចូលក្នុងប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ នៃខែដែលប្រាក់ទាំងនោះត្រូវបានបើកឱ្យនិយោជិត។ ចំនួនប្រាក់ដែលត្រូវបូកបញ្ចូលក្នុងប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ គឺជាចំនួនប្រាក់បុរេប្រទាន ប្រាក់ឱ្យខ្ចីឬប្រាក់រំដោះមិនទាន់កាត់ទុកប្រាក់ពន្ធ។

៤- ប្រាក់បុរេប្រទាន ប្រាក់ឱ្យខ្ចីឬប្រាក់រំដោះដែលនិយោជិតទូទាត់សងវិញ ត្រូវកាត់បន្ថយពីប្រាក់បៀវត្សជាប់ពន្ធប្រចាំខែដែលនិយោជិតបានបង់សងវិញ។ ចំពោះប្រាក់កម្ចី ការកាត់បន្ថយត្រូវបានអនុញ្ញាតតែត្រឹមចំនួនប្រាក់ដើមតែប៉ុណ្ណោះ រីឯការប្រាក់ត្រូវកត់ត្រាជាប្រាក់ចំណូលរបស់និយោជក។

៥- ដូចមានចែងក្នុងកថាខណ្ឌ ៤ នៃមាត្រា ៥២ នៃច្បាប់ស្ដីពីសារពើពន្ធ ប្រាក់បៀវត្សប្រចាំខែរបស់រូបវន្តបុគ្គលនិវាសនជន ឬអនិវាសនជន ត្រូវជាប់ពន្ធលើប្រាក់បៀវត្ស ទោះបីជាប្រាក់បៀវត្សនោះបើកនៅទីណាក៏ដោយ។

**ប្រការ ១៣.- កូនក្នុងបន្ទុក**

១- កូនក្នុងបន្ទុក គឺជាកូនរបស់និយោជិតដែលមានអាយុមិនលើសពី ១៤ឆ្នាំ ឬជាកូនរបស់និយោជិត ដែលជាសិស្ស ឬនិស្សិតមានអាយុមិនលើសពី ២៥ឆ្នាំ កំពុងសិក្សាពេញម៉ោងនៅក្នុងគ្រឹះស្ថានសិក្សាដែលមានការទទួលស្គាល់ជាផ្លូវការ។

២- កូនក្នុងបន្ទុកត្រូវមានសំបុត្រកំណើត និង/ឬឯកសារគាំទ្រពាក់ព័ន្ធ។

៣- បើសិនជាកូនស្ថិតក្នុងបន្ទុក ដែលមានអាយុលើសពី ១៤ឆ្នាំ ដល់ ២៥ឆ្នាំ ជាសិស្សឬនិស្សិតកំពុងសិក្សាពេញម៉ោងនៅក្នុងគ្រឹះស្ថានសិក្សាដែលមានការទទួលស្គាល់ជាផ្លូវការ និយោជកត្រូវបង្ហាញវិញ្ញាបនបត្របញ្ជាក់ការសិក្សាដែលបញ្ជាក់យ៉ាងច្បាស់លាស់ថា កូននោះជាសិស្សឬនិស្សិតកំពុងសិក្សាពេញម៉ោងពិតប្រាកដមែន។

៤- រដ្ឋបាលសារពើពន្ធ មានសិទ្ធិបដិសេធនូវវិញ្ញាបនបត្របញ្ជាក់ការសិក្សារបស់គ្រឹះស្ថានសិក្សាណាដែលកន្លងមកធ្លាប់បានចេញវិញ្ញាបនបត្របញ្ជាក់ការសិក្សាក្លែងបន្លំ។

៥- កូនស្ថិតក្នុងបន្ទុកនៅតែត្រូវបានចាត់ទុកថា ជាកូនស្ថិតក្នុងបន្ទុកដដែលនៅក្នុងខែដែលកូននោះឈានចូលអាយុ ១៥ឆ្នាំ ឬក្នុងខែដែលសិស្សឬនិស្សិតបញ្ចប់ការសិក្សារបស់ខ្លួនឬឈានចូលអាយុ ២៦ឆ្នាំ។

**ប្រការ ១៤.- អត្រាពន្ធលើប្រាក់បៀវត្សប្រចាំខែរបស់និយោជិតដែលត្រូវកាត់ទុក**

១- សម្រាប់និយោជិតនិវាសនជន ប្រាក់ពន្ធត្រូវបង់ត្រូវកំណត់លើប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ និងត្រូវកាត់ទុកដោយនិយោជកតាមអត្រាកំណើនតាមថ្នាក់ដូចមានចែងក្នុងអនុក្រឹត្យស្តីពីតារាងភាគនៃប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំ និងតារាងភាគនៃប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ។

២- សម្រាប់អ្នកជាប់ពន្ធអនិវាសនជន ប្រាក់ពន្ធត្រូវកាត់ទុកដោយអ្នកបើកប្រាក់ឱ្យតាមអត្រា ២០ភាគរយ លើរាល់ការទូទាត់ប្រាក់បៀវត្សជាប់ពន្ធដែលមានចែងក្នុងកថាខណ្ឌ ៣ នៃមាត្រា ៤៦ នៃច្បាប់ស្តីពីសារពើពន្ធ។ ពន្ធនេះ គឺជាពន្ធចុងក្រោយនៃពន្ធលើប្រាក់បៀវត្សសម្រាប់អនិវាសនជនជាអ្នកទទួលប្រាក់បៀវត្ស។

## ជំពូកទី៣
## អត្ថប្រយោជន៍បន្ថែម

**ប្រការ ១៥.- ការកំណត់អត្ថប្រយោជន៍បន្ថែម**

១- ដូចមានចែងក្នុងកថាខណ្ឌ ៨ នៃមាត្រា ៤២ ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ អត្ថប្រយោជន៍បន្ថែមរួមមានទំនិញសេវា ឬអត្ថប្រយោជន៍ជាសាច់ប្រាក់ ឬវត្ថុផ្សេងទៀតដែលនិយោជកផ្តល់ឱ្យដោយផ្ទាល់ ឬដោយប្រយោលដល់រូបវន្តបុគ្គលចំពោះសកម្មភាពបម្រើការងារដែលរូបវន្តបុគ្គលនោះបានបំពេញដើម្បីជាផលប្រយោជន៍ដល់និយោជក។

២- អត្ថប្រយោជន៍ដែលនិយោជកផ្តល់ឱ្យដោយផ្ទាល់ ឬដោយប្រយោលដល់រូបវន្តបុគ្គល ត្រូវជាប់ពន្ធលើអត្ថ-ប្រយោជន៍បន្ថែម។ អត្ថប្រយោជន៍ទាំងនោះ ជាអាទិ៍មាន÷

ក- យានជំនិះគ្រប់ប្រភេទ

ខ- ម្ហូបអាហារ

គ- លំនៅឋាន ការស្នាក់នៅ

ឃ- ទឹក ភ្លើង ទូរស័ព្ទ

ង- អ្នកបម្រើការងារក្នុងលំនៅឋាន

ច- ប្រាក់ឱ្យខ្ចីដោយគិតការប្រាក់ទាបជាងការប្រាក់ទីផ្សារ។ អត្រាការប្រាក់ទីផ្សារដែលត្រូវយកមកអនុវត្ត ត្រូវកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ឆ- ការលក់ទំនិញចុះថ្លៃ

ជ- ជំនួយផ្ទែកអប់រំសម្រាប់និយោជិត ដែលមិនមែនជាចំណែកណាមួយនៃកម្មវិធីបណ្ដុះបណ្ដាលទាក់ទិន ផ្ទាល់ទៅនឹងការបំពេញការងាររបស់និយោជិតនោះ

ឈ- ជំនួយផ្នែកអប់រំសម្រាប់កូនរបស់និយោជិត

ញ- បុព្វលាភធានារ៉ាប់រងអាយុជីវិត ឬសុខភាព លើកលែងតែមានផ្ដល់អត្ថប្រយោជន៍បន្ថែមដូចគ្នាឱ្យដល់ និយោជិតគ្រប់គ្នាដោយគ្មានការបែងចែកតាមតួនាទី ឬមុខងារ

ដ- ចំណែកនៃការឧបត្ថម្ភលើចំណាយដែលមិនសមហេតុផល និងមិនចាំបាច់សម្រាប់អាជីវកម្មរបស់ និយោជក

ឋ- ចំនួនប្រាក់បង់ចូលមូលនិធិសុខុមាលភាពសង្គមដែលលើសពីកម្រិតដែលច្បាប់បានអនុញ្ញាត

ឌ- ចំនួនប្រាក់បង់ចូលបេឡាសោធនដែលលើសពី ១០ភាគរយ នៃប្រាក់បៀវត្សប្រចាំខែគ្មានបូកអត្ថ-ប្រយោជន៍បន្ថែមរបស់និយោជិត

ឍ- ចំណាយសម្រាប់ការទទួលភ្ញៀវ ការកម្សាន្ត ការសម្រាកលំហែ ឬការប្រើប្រាស់មធ្យោបាយណាមួយ ដែលទាក់ទិននឹងសកម្មភាពទាំងនេះ ដែលមិនមែនជាចំណែកណាមួយនៃទំនាក់ទំនងបម្រើការងារ

ណ- ការផ្ដល់ឱ្យចំណែកណាមួយនៃភាគហ៊ុន ឬទុនក្រុមហ៊ុន។

**ប្រការ ១៦.- ការប្រើប្រាស់យានយន្ត**

ការប្រើប្រាស់យានយន្តក្នុងការដឹកនិយោជិត មិនត្រូវជាប់ពន្ធលើអត្ថប្រយោជន៍បន្ថែមទេ បើសិនបំពេញ លក្ខខណ្ឌ ៣ ខាងក្រោម÷

ក- យានយន្តត្រូវបានចតទុកនៅក្នុងទីកន្លែងធ្វើអាជីវកម្មនៅក្រោយពេលម៉ោងធ្វើការ និងនៅក្នុងថ្ងៃឈប់ សម្រាកការងារ

ខ- យានយន្តមិនត្រូវបានប្រគល់យ៉ាងជាក់លាក់ទៅឱ្យនិយោជិតណាម្នាក់ ឬសមាជិកគ្រួសាររបស់និយោជិត ណាម្នាក់នៅក្រោយពេលម៉ោងធ្វើការ

គ- យានយន្តមិនត្រូវបានប្រើប្រាស់ដោយនិយោជិត ឬបុគ្គលនៅក្នុងបន្ទុករបស់និយោជិតដើម្បីធ្វើការងារ ផ្ទាល់ខ្លួន។

**ប្រការ ១៧.- អត្រាពន្ធលើអត្ថប្រយោជន៍បន្ថែម**

ចំពោះអត្ថប្រយោជន៍បន្ថែម ជារៀងរាល់ខែនិយោជកត្រូវកាត់ទុកនិងបង់ប្រាក់ពន្ធតាមកាលកំណត់ តាមអត្រា ២០ភាគរយ នៃតម្លៃសរុបរបស់អត្ថប្រយោជន៍បន្ថែមដែលបានផ្ដល់ឱ្យនិយោជិតទាំងអស់។ តម្លៃនៃអត្ថប្រយោជន៍បន្ថែម គឺជាតម្លៃទីផ្សាររួមទាំងពន្ធអាករទាំងអស់។

**ប្រការ ១៨.- តម្លៃជាប់ពន្ធនៃអត្ថប្រយោជន៍បន្ថែម**

១- តម្លៃនៃអត្ថប្រយោជន៍បន្ថែម គឺជាតម្លៃទីផ្សាររួមទាំងពន្ធអាករទាំងអស់នៃអត្ថប្រយោជន៍បន្ថែមដែលបាន ផ្ដល់ឱ្យ។ ចំពោះទ្រព្យដែលត្រូវរំលស់ តម្លៃទីផ្សារនៃអត្ថប្រយោជន៍បន្ថែម គឺជាចំនួនប្រាក់រំលស់ដែលបានអនុញ្ញាតដូចមាន

ចែងក្នុងវាក្យខណ្ឌ គ នៃកថាខណ្ឌ ១ នៃមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ។ ក្នុងករណីរដ្ឋបាលសារពើពន្ធមិនឯកភាពចំពោះតម្លៃទីផ្សារនៃអត្ថប្រយោជន៍បន្ថែមដែលកំណត់ដោយនិយោជក រដ្ឋបាលសារពើពន្ធមានសិទ្ធិកំណត់ឡើងវិញនូវប្រាក់ពន្ធត្រូវបង់ដូចមានចែងក្នុងមាត្រា ១១៩ នៃច្បាប់ស្តីពីសារពើពន្ធ។

២- អត្ថប្រយោជន៍បន្ថែមត្រូវជាប់ពន្ធនៅក្នុងខែដែលអត្ថប្រយោជន៍បន្ថែមនោះ ត្រូវបានផ្តល់ទៅឱ្យនិយោជិត ដោយមិនត្រូវគិតពីកាលបរិច្ឆេទដែលអត្ថប្រយោជន៍បន្ថែមនោះត្រូវក្លាយជាបន្ទុករបស់និយោជកទេ។

## ជំពូកទី៤

## ឥណទានពន្ធបរទេស

### ប្រការ ១៩.- គោលការណ៍ទូទៅនៃឥណទានពន្ធបរទេស

១- រូបវន្តបុគ្គលនិវាសនជនដែលបានទទួលប្រាក់បៀវត្សប្រភពបរទេស និងបានបង់ពន្ធតាមច្បាប់ពន្ធដារបរទេស ត្រូវបានទទួលនូវឥណទានពន្ធសម្រាប់កាត់កងពីប្រាក់ពន្ធលើប្រាក់បៀវត្សដែលត្រូវបង់នៅព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែលុះណាតែមានការបង្ហាញឯកសារបញ្ជាក់អំពីការបង់ពន្ធនៅបរទេសនោះ។

២- ដើម្បីគណនាប្រាក់ពន្ធលើប្រាក់បៀវត្សដែលត្រូវបង់នៅព្រះរាជាណាចក្រកម្ពុជា មុនពេលកាត់ឥណទានពន្ធ ត្រូវយកចំនួនសរុបនៃប្រាក់បៀវត្សដែលបានទទួលពីប្រភពកម្ពុជានិងប្រភពបរទេសមកគិត។

៣- ឥណទានពន្ធត្រូវបានកំណត់ដាច់ដោយឡែកពីគ្នា សម្រាប់ប្រាក់ពន្ធដែលបានបង់ដោយរូបវន្តបុគ្គលនិវាសនជនកម្ពុជានៅប្រទេសក្រៅនីមួយៗ។ ឥណទានពន្ធដែលអនុញ្ញាតឱ្យកាត់កងសម្រាប់ពន្ធលើប្រាក់បៀវត្ស ដែលបានបង់នៅប្រទេសក្រៅណាមួយ គឺចំនួនដែលទាបជាងគេក្នុងចំណោម÷

- ក- ប្រាក់ពន្ធដែលបានបង់ជាក់ស្តែងនៅប្រទេសក្រៅណាមួយនោះ
- ខ- ចំនួនដែលបានមកពីការយកប្រាក់ពន្ធលើប្រាក់បៀវត្សសរុបពីគ្រប់ប្រភព សម្រាប់រយៈពេលជាមួយគ្នាដែលគណនាតាមអត្រាពន្ធក្នុងមាត្រា ៤៧ ថ្មី (បី) នៃច្បាប់ស្តីពីសារពើពន្ធ ទៅគុណនឹងផលចែករវាងប្រាក់បៀវត្សដែលបានទទួលនៅប្រទេសក្រៅនោះ និងប្រាក់បៀវត្សសរុបពីគ្រប់ប្រភព។

៤- ឥណទានពន្ធបរទេសអាចផ្តល់ឱ្យបាន លុះណាតែអ្នកជាប់ពន្ធនិវាសនជនបានបំពេញបែបបទ ព្រមទាំងផ្តល់ឯកសារនានាកំណត់ដោយរដ្ឋបាលសារពើពន្ធ ជាពិសេសសេចក្តីបញ្ជាក់របស់អ្នកទូទាត់ប្រាក់ពន្ធលើប្រាក់បៀវត្សនៅបរទេសនិងរដ្ឋបាលសារពើពន្ធបរទេសនោះ។

### ប្រការ ២០.- ឥណទានសម្រាប់ប្រាក់ពន្ធបរទេសដែលនិវាសនជនបានបង់

១- ឥណទានពន្ធដែលអនុញ្ញាត ត្រូវកំណត់ប្រចាំឆ្នាំដោយផ្អែកលើប្រាក់បៀវត្សសរុបដែលបានទទួលគ្មានបូកបញ្ចូលនូវអត្ថប្រយោជន៍បន្ថែមនានាដែលត្រូវជាប់ពន្ធលើអត្ថប្រយោជន៍បន្ថែម។

២- ដូចមានចែងក្នុងកថាខណ្ឌ ២ នៃមាត្រា ៥០ នៃច្បាប់ស្តីពីសារពើពន្ធ ភស្តុតាងឯកសារបញ្ជាក់ពីការបង់ពន្ធបរទេស មានដូចតទៅ÷

- ក- សេចក្តីបញ្ជាក់របស់និយោជក ឬកិច្ចសន្យាបម្រើការងារដែលមានបញ្ជាក់លម្អិតអំពីការងារបានបំពេញ កាលបរិច្ឆេទ និងចំនួនប្រាក់បៀវត្សបានទូទាត់សម្រាប់ការងារនៅប្រទេសក្រៅ
- ខ- ច្បាប់ចម្លងនៃទម្រង់ឯកសារដែលនិយោជកបានដាក់ជូនរដ្ឋបាលសារពើពន្ធប្រទេសក្រៅនោះ ដើម្បីបង់ប្រាក់ពន្ធ

គ- បង្កាន់ដៃទទួលប្រាក់ពន្ធបរទេសដែលរដ្ឋបាលសារពើពន្ធប្រទេសក្រៅបានចេញឱ្យ។

៣- ឯកសារដូចបញ្ជាក់ក្នុងកថាខណ្ឌ ២ នៃប្រការនេះ ដែលធ្វើជាភាសាផ្សេងទៀតក្រៅពីភាសាខ្មែរ ឬអង់គ្លេស ត្រូវភ្ជាប់មកជាមួយនូវសេចក្ដីបកប្រែដែលមានការបញ្ជាក់ទទួលស្គាល់ត្រឹមត្រូវ។

## ជំពូកទី៥

## ភាតព្វកិច្ចរបស់និយោជក និងការដាក់លិខិតប្រកាស

### ប្រការ ២១.- ភាតព្វកិច្ចរបស់និយោជកក្នុងការកត់ត្រា ថែរក្សា និងផ្ដល់ឯកសារនិងកំណត់ត្រានានា

ដូចមានចែងក្នុងកថាខណ្ឌ ៣ នៃមាត្រា ៥៤ នៃច្បាប់ស្ដីពីសារពើពន្ធ និយោជកត្រូវ÷

១- រក្សាទុកនៅក្នុងឯកសារបម្រើការងាររបស់និយោជិតម្នាក់ៗនូវព័ត៌មាន ដូចតទៅ÷

ក- នាម និងគោត្តនាមរបស់និយោជិត

ខ- ភេទ

គ- ថ្ងៃ ខែ ឆ្នាំ កំណើត និងទីកន្លែងកំណើត

ឃ- សញ្ជាតិ

ង- ទីលំនៅ ឬកន្លែងស្នាក់នៅ

ច- មុខងារ

ឆ- កាលបរិច្ឆេទចូលបម្រើការងារ និងឈប់បម្រើការងារ បើសិនជាមាន

ជ- ប្រាក់បៀវត្សប្រចាំខែដុលគ្មានអត្ថប្រយោជន៍បន្ថែម

ឈ- អត្ថប្រយោជន៍បន្ថែមដែលមានចុះក្នុងកិច្ចសន្យាបម្រើការងារ។

២- កត់ត្រាក្នុងឯកសារទូទាត់លើរាល់ការទូទាត់ដល់និយោជិតនូវព័ត៌មាន ដូចតទៅ÷

ក- ប្រាក់បៀវត្សប្រចាំខែសរុបគ្មានអត្ថប្រយោជន៍បន្ថែមដែលបានបើកឱ្យនិយោជិត

ខ- ព័ត៌មានលម្អិតលើចំណាយបន្ទាប់បន្សំដែលមិនជាប់ពន្ធលើអត្ថប្រយោជន៍បន្ថែម ដូចជាប្រាក់ម៉ោងបន្ថែម ប្រាក់សំណងនូវចំណាយ ហើយនិងការទូទាត់ ឬបុព្វលាភដទៃទៀត

គ- ការបង់ចូលមូលនិធិសុខុមាលភាពសង្គមតាមការតម្រូវនៃច្បាប់ការងារ

ឃ- ប្រាក់បៀវត្សជាប់ពន្ធប្រចាំខែរបស់និយោជិតដែលត្រូវជាប់ពន្ធលើប្រាក់បៀវត្ស តាមមាត្រា ៤៧ ថ្មី (បី) នៃច្បាប់ស្ដីពីសារពើពន្ធ

ង- ប្រាក់ពន្ធកាត់ទុកតាមមាត្រា ៤៧ ថ្មី (បី) នៃច្បាប់ស្ដីពីសារពើពន្ធ។

៣- កត់ត្រាអត្ថប្រយោជន៍បន្ថែមដែលបានទូទាត់ឱ្យដល់និយោជិត ដោយមានបញ្ជាក់យ៉ាងច្បាស់លាស់នូវប្រភេទ និងតម្លៃនៃអត្ថប្រយោជន៍បន្ថែមនោះ។

៤- ក្នុងករណីដែលនិយោជកទិញអត្ថប្រយោជន៍បន្ថែមសម្រាប់ជាប្រយោជន៍ដល់និយោជិត និយោជកត្រូវរក្សាទុកនូវវិក្កយបត្រ ឬកិច្ចសន្យាទិញអត្ថប្រយោជន៍បន្ថែមនោះក្នុងឯកសារគណនេយ្យរបស់សហគ្រាស។

៥- កត់ត្រាក្នុងតារាងបើកប្រាក់បៀវត្ស និងអត្ថប្រយោជន៍បន្ថែមនូវព័ត៌មានរបស់និយោជិតម្នាក់ៗ ដូចខាងក្រោម÷

ក- លាភការដុលរបស់និយោជិតដែលត្រូវជាប់ពន្ធលើប្រាក់បៀវត្ស

ខ- មូលដ្ឋានកំណត់ពន្ធដែលត្រូវអនុវត្តការកាត់ទុកប្រាក់ពន្ធតាមមាត្រា ៤៧ ថ្មី (បី) នៃច្បាប់ស្ដីពីសារពើពន្ធ

គ- ចំនួនប្រាក់ពន្ធកាត់ទុក

ឃ- តម្លៃនៃអត្ថប្រយោជន៍បន្ថែមដែលបានផ្ដល់ឱ្យ។

**ប្រការ ២២.- ការដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធ**

ការបង់ប្រាក់ពន្ធលើប្រាក់បៀវត្ស និងប្រាក់ពន្ធលើអត្ថប្រយោជន៍បន្ថែមដែលបានកាត់ទុក ត្រូវដាក់លិខិតប្រកាសពន្ធ និងបង់ប្រាក់ពន្ធដែលបានកាត់ទុកដោយនិយោជកជូនរដ្ឋបាលសារពើពន្ធ ទៅតាមទម្រង់ដែលរដ្ឋបាលសារពើពន្ធបានកំណត់យ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ពីខែដែលបានកាត់ទុក។

លិខិតប្រកាសពន្ធ អាចត្រូវបានត្រួតពិនិត្យ និងជាកម្មវត្ថុនៃនីតិវិធីក្នុងការកំណត់ពន្ធឡើងវិញប្រសិនបើមាន។ ក្នុងករណីដែលនិយោជកមិនបានដាក់លិខិតប្រកាសពន្ធលើប្រាក់បៀវត្ស រដ្ឋបាលសារពើពន្ធ អាចកំណត់ពន្ធជាឯកតោភាគីបាន។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**ប្រការ ២៣.- និរាករណ៍**

ប្រកាសលេខ ១១៧៣ សហវ.ពដ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៣ ស្តីពីពន្ធលើប្រាក់បៀវត្ស និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ២៤.- ការអនុវត្ត**

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋាន ឬអគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ២កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែកញ្ញា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី-ខេត្ត
- ដូចប្រការ ២៤ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ